នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Aug-2014, 14:58
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់បំផុត** ***ដោយភាគីតែម្ខាង***

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: **ចូរទៅជាសាធារណៈ**

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងការជូនដំណឹង ទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង ចូលរួមក្នុងកិច្ចស៊ើបសួរ និងសុំឯកសារពេញលេញនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញាអន្តរជាតិ
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
សហចៅក្រមស៊ើបអង្កេត
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Judge Mark B. HARMON

**ចម្លងជូន:**
សហព្រះរាជអាជ្ញាជាតិ
លោកស្រី ជា លាង

សហមេធាវីជនសង្ស័យ
លោក អាង ឧត្តម
លោក Michael G.KARNAVAS

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាអន្តរជាតិ ("សពរអ") សូមឆ្លើយតបទៅនឹង "ការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សចសអ") ទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿងនិងចូលរួមក្នុងកិច្ចស៊ើបសួរ(D82) និងសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងសម្ភារៈគាំទ្រ(D82/2)" ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ ("ការជូនដំណឹង")[1]។

២. អនុលោមតាមមាត្រា៧.២ នៃ*សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ* សពរអ សូមការអនុញ្ញាតដាក់សេចក្តីសន្និដ្ឋាននេះជាភាសាអង់គ្លេសតែមួយភាសាសិន ដោយភាសាខ្មែរនឹងដាក់តាមក្រោយ។ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ សពរអ បានធ្វើសំណើជាមុនក្នុងការសុំដាក់សេចក្តីសន្និដ្ឋាននេះតែមួយភាសា ដោយផ្អែកលើមូលដ្ឋានដូចតទៅ៖ ក) បញ្ហានេះមានការពាក់ព័ន្ធទៅនឹងប្រវត្តិនីតិវិធីដ៏ទូលំទូលាយ និងដ៏ស្មុគស្មាញ ដែលមិនអាចឲ្យយើងដាក់ឯកសារទាំងពីរភាសាក្នុងពេលកំណត់តែមួយបាន (១០ថ្ងៃនៃថ្ងៃធ្វើការ) និង ខ) ធនធានបកប្រែរបស់សហព្រះរាជអាជ្ញា កំពុងជាប់រវល់ក្នុងការងារបកប្រែឯកសារមួយចំនួនដែលត្រូវដាក់ក្នុងពេលជួនគ្នា ក្នុងសំណុំរឿងផ្សេងទៀត[2]។ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤ សចសអ បានទទួលយកហេតុផលទាំងនេះ និងបានបង្គាប់ឲ្យ សពរអ បង្កើតទម្រង់ជាក់លាក់នៃសំណើសុំ ដូចមាននៅក្នុងសេចក្តីសន្និដ្ឋាននេះ[3]។ សពរអ សូមស្នើដោយគោរពដល់ សចសអ ទទួលយកការដាក់ឯកសារតែមួយភាសាអង់គ្លេសនេះសិន និងសូមជូនដំណឹងដល់ សចសអ ថា ច្បាប់បកប្រែជាភាសាខ្មែរ អាចនឹងត្រូវដាក់នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៤ ឬមុនកាលបរិច្ឆេទនេះ។

៣. សពរអ បានស្នើចំណាត់ថ្នាក់សម្រាប់សេចក្តីសន្និដ្ឋាននេះ គឺសម្ងាត់បំផុត *ដោយភាគីតែម្ខាង*។ មូលហេតុ គឺដោយសារសេចក្តីសន្និដ្ឋាននេះមានការលើកយោង និងមានសេចក្តីសង្ខេបមួយចំនួនធំអំពីសម្ភារៈភស្តុតាងដែលជនសង្ស័យ និងសហមេធាវីរបស់គាត់ មិនអាចចូលពិនិត្យមើលបាននៅពេលបច្ចុប្បន្ននេះ។ សពរអ គោរពតាម សចសអ លើបញ្ហានៃការធ្វើចំណាត់ថ្នាក់ និងបានត្រៀមខ្លួនរួចជាស្រេចដើម្បីដាក់សេចក្តីសន្និដ្ឋានដែលបានស្នើឡើងនេះជាច្បាប់កោសលប់ បើសិន សចសអ យល់ថា សមស្រប[4]។

---

[1] **D82/3** ការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ(D82) និងសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងសម្ភារៈគាំទ្រ(D82/2), ១០ កក្កដា ២០១៤។

[2] អ៊ីម៉ែល ពីលោក Tarik Abdulhak, ជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញា ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤។

[3] អ៊ីម៉ែល ពីលោក David Boyle, កុងស៊ុលតង់ផ្នែកច្បាប់, ការិយាល័យសហចៅក្រមស៊ើបអង្កេត, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤។

[4] មាត្រា៩.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ និងការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនឹងសំណុំរឿង។

## II. ប្រវត្តិនីតិវិធី

៤. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ("សចសអប") បានចេញ "ការជូនដំណឹងអំពីសិទ្ធិជនសង្ស័យ [វិធាន២១ (១)(ឃ)]" ដោយក្នុងនោះគាត់បានជំរាបជូន មាស មុត ("ជនសង្ស័យ") ថា៖ ក) គាត់ជាជនសង្ស័យដែលមានឈ្មោះនៅក្នុងកិច្ចស៊ើបសួរនេះទាក់ទងនឹងឧក្រិដ្ឋកម្មទាំងឡាយដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ខ) គាត់មានសិទ្ធិរកមេធាវី សិទ្ធិចូលពិនិត្យមើលសំណុំរឿង និងសិទ្ធិនៅស្ងៀមមិនឆ្លើយតប[5] ("សេចក្ដីសម្រេចអំពីសិទ្ធិចូលពិនិត្យមើលសំណុំរឿង")។ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ សចសអប បានចេញ "សេចក្ដីសម្រេចស្ដីពីយុត្តាធិការបុគ្គល និងគោលនយោបាយស៊ើបអង្កេតទាក់ទងនឹង មាស មុត" ("សេចក្ដីសម្រេចស្ដីពីយុត្តាធិការ") ដែលក្នុងសេចក្ដីសម្រេចនេះគាត់បានរកឃើញថា ដោយផ្អែកលើភ័ស្តុតាងដែលបានយោងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ និងភ័ស្តុតាងបន្ថែមដែលប្រមូលបានក្នុងពេលស៊ើបសួរ៖ ក) មាស មុត គឺជាមន្ត្រីខ្មែរក្រហមម្នាក់ និងថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើរូបគាត់ ត្រូវបានកំណត់យ៉ាងគ្រប់គ្រាន់ និងក្នុងរបៀបមួយដែលអាចជឿទុកចិត្តបាន[6] និង ខ) មាស មុត អាចត្រូវបានពិចារណាថា ជាបុគ្គលមួយរូបនៃជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនាសម័យកាលចន្លោះថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ថ្ងៃទី ៦ មករា ១៩៧៩[7]។

៥. នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ ប្រធានអង្គភាពគាំពារការការពារក្ដី បានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតថា ជនសង្ស័យបានជ្រើសរើស អាង ឧត្តម និង Michael Karnavas ធ្វើជាមេធាវីរបស់គាត់ និងបានសុំឱ្យសហចៅក្រមស៊ើបអង្កេតកត់សំគាល់ពីការចាត់តាំងពួកគាត់ទាំងពីរធ្វើជាសហមេធាវីរបស់ជនសង្ស័យ[8]។ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឱ្យច្រានចោលការចាត់តាំងនេះ ដោយសារមូលហេតុនៃអត្ថិភាពនៃទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន[9]។ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ និងថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ សហមេធាវីបានដាក់ "សំណើរបស់ មាស មុត សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើប

---

[5] **D30** ការជូនដំណឹងអំពីសិទ្ធិជនសង្ស័យ [វិធាន២១(១)(ឃ)], ២៤ កុម្ភៈ ២០១២ ត្រង់កថាខណ្ឌ ១-៥។

[6] **D48** សេចក្ដីសម្រេចអំពីយុត្តាធិការបុគ្គល និងគោលនយោបាយស៊ើបសួរទាក់ទងនឹងជនសង្ស័យ មាស មុត, ២ ឧសភា ២០១២, កថាខណ្ឌ ៧-១០។

[7] ដដែលដូចខាងលើ, ត្រង់កថាខណ្ឌ២៧ និងការសម្រេចបញ្ចប់លើសេចក្ដីសម្រេចនេះ។

[8] **D56** លិខិត មានចំណងជើងថា "ការចាត់តាំងសហមេធាវី ធ្វើតំណាងលោក មាស មុត, ជនសង្ស័យម្នាក់ក្នុងសំណុំរឿង ០០៣", ១៨ ធ្នូ ២០១២។

[9] **D56/1** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យច្រានចោលការចាត់តាំងសហមេធាវីចាត់តាំង ដោយផ្អែកលើមូលហេតុនៃទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន, ២៤ ធ្នូ ២០១៤។

សួរ”[10] (“សំណើពិនិត្យមើលសំណុំរឿង”) និង “សំណើសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងសម្ភារៈគាំទ្រ”[11] (“សំណើបន្ថែម”)។

៦. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ សចសអ បានផ្ដល់ការអនុញ្ញាតតាមសំណើរបស់ សពអ និងបានច្រានចោលការចាត់តាំងសហមេធាវី[12]។ សហមេធាវី បានប្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេចនេះ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤[13] ហើយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ អង្គបុរេជំនុំជម្រះបានតម្កល់បណ្ដឹងឧទ្ធរណ៍ដោយបានទទួលស្គាល់ អាង ឧត្ដម និង Michael Karnavas ជាសហមេធាវីជនសង្ស័យ[14]។

៧. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ សចសអ បានចេញការជូនដំណឹងមួយដោយជំរាបភាគីថា គាត់កំពុងតែពិចារណាលើសេចក្ដីសម្រេចអំពីការពិនិត្យមើលសំណុំរឿង និងសេចក្ដីសម្រេចអំពីយុត្តាធិការ ក្នុងទស្សនៈយល់ឃើញមួយអំពីការជំនុំជម្រះលើសំណើសុំពិនិត្យមើលសំណុំរឿង និងសំណើសុំបន្ថែម[15]។ សចសអ បានអញ្ជើញឲ្យភាគីដាក់សេចក្ដីសង្កេតទៅលើការពិចារណានៅលើសេចក្ដីសម្រេចទាំងនេះ។

## III. ឋានៈជាមេដឹកនាំជាន់ខ្ពស់/ជាជនដែលទទួលខុសត្រូវខ្ពស់បំផុតរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យ

៨. សេចក្ដីសម្រេចអំពីយុត្តាធិការ ដោយអនុវត្តតាមមគ្គុទេសណែនាំខាងផ្លូវច្បាប់ ដូចមានចែងនៅក្នុងសាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០១ របស់អង្គជំនុំជម្រះតុលាការកំពូល សចសអប

[10] **D82** សំណើរបស់ មាស មុត សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ, ២៩ សីហា ២០១៣។

[11] **D82/2** សំណើសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងសម្ភារៈគាំទ្រ, ២៦ កញ្ញា ២០១៣។

[12] **D56/18** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលស្នើឲ្យបដិសេធការតែងតាំងសហមេធាវីការពារក្ដី មាស មុត នៅលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន, ១០ មករា ២០១៤។

[13] **D56/19** សៀវភៅចុះបណ្ដឹងឧទ្ធរណ៍នៃបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ដែលស្នើឲ្យបដិសេធការតែងតាំងសហមេធាវីការពារក្ដី មាស មុត នៅលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន, ១៣ មករា ២០១៤។ **D56/19/24** បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត Harmon លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យច្រានចោលការតែងតាំងសហមេធាវីរបស់ មាស មុត ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍មិនអាចផ្សះផ្សាបាន, ១២ មីនា ២០១៤។

[14] **D56/19/36** សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ច្រានចោលការតែងតាំង អាង ឧត្ដម និង Michael KARNAVAS ជាសហមេធាវី, ៣០ មិថុនា ២០១៤។

[15] **D82/3** ការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត(D82) និងសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងសម្ភារៈគាំទ្រ (D82/2), ១០ កក្កដា ២០១៤ ត្រង់កថាខណ្ឌ១៦។

បានសម្រេចដោយផ្អែកលើមូលដ្ឋាននៃតម្លៃភ័ស្តុតាង[16] ថា មាស មុត ជាបុគ្គល "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅកម្ពុជាក្នុងសម័យកាលពីឆ្នាំ១៩៧៥ - ១៩៧៩ ហេតុដូច្នេះ នេះជាការលើកឡើងអំពីបញ្ហាគោលនយោបាយ/ឆន្ទានុសិទ្ធិខាងផ្នែកស៊ើបអង្កេត ដែលគេមិនអាចធ្វើការវិនិច្ឆ័យបាន[17]។ ដើម្បីឈានដល់សេចក្តីសម្រេចនេះ សចសអប បានគិតគូទៅលើភ័ស្តុតាងទាំងប៉ុន្មានដែលគេអាចរកបាននាពេលនោះ និងវិសាលភាពនៃការពិចារណាផ្សេងៗទៀត ដោយផ្តោតលើទម្ងន់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប្រឆាំងជនសង្ស័យ[18] ព្រមទាំងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[19]។ សចសអប សម្រេចថា ដោយផ្អែកលើការសន្និដ្ឋានដែលថា មាស មុត ជាជន "ដែលទទួលខុសត្រូវខ្ពស់បំផុត" គេមិនចាំបាច់ពិចារណាថា តើជនសង្ស័យស្ថិតក្នុងជំពូកនៃមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ[20] ឬអត់នោះទេ។

៩. សពអ សន្និដ្ឋានថា សេចក្តីសម្រេចអំពីយុត្តាធិការ គឺជាការត្រឹមត្រូវ និងមានការគាំទ្រយ៉ាងពេញទំហឹងដោយភ័ស្តុតាងដែលបានលើកយោងក្នុងនោះ។ ភ័ស្តុតាងដែលប្រមូលបានតាំងពីមានសេចក្តីសម្រេចអំពីយុត្តាធិការ បានផ្តល់ការគាំទ្របន្ថែមទៀតលើការសម្រេចរបស់ សចសអប និងបានកំណត់ថា មាស មុត ស្ថិតក្នុងជំពូកមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ។ ភ័ស្តុតាងថ្មីនេះបង្ហាញឲ្យឃើញពីការទទួលខុសត្រូវកម្រិតខ្ពស់របស់ មាស មុត ដែលគាត់បានកាន់កាប់ក្នុងនាមគាត់ជាមេដឹកនាំយោធា និងជាមេដឹកនាំនយោបាយម្នាក់ ព្រមទាំងអំពីទំហំ វិសាលភាព និងទម្ងន់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយ មាស មុត និងកងកម្លាំងនៅក្រោមការត្រួតត្រារបស់គាត់។ ត្រង់នេះក៏មានតម្លៃស្មើនឹង "ភ័ស្តុតាងច្បាស់លាស់ និងគួរឲ្យជឿបាន" ផងដែរថា មាស មុត ត្រូវមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដូចបានអះអាងនៅក្នុងសំណុំរឿងនេះ។ ដូច្នេះ មាស មុត នៅក្នុងដំណាក់កាលនេះ គួរត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋទាំងនោះ។ ការផ្តល់សេចក្តីសង្ខេបអំពីភ័ស្តុតាងទាំងនេះ ត្រូវបានប្រមូលតាំងពីមានសេចក្តីសម្រេចអំពីយុត្តាធិការ ដូចបានបង្ហាញជូនក្នុងវាក្យខណ្ឌ II ក និង II ខ ខាងក្រោម។

## *II. ក. ភ័ស្តុតាងថ្មីអំពីកម្រិតនៃសិទ្ធិអំណាចរបស់ មាស មុត*

១០. ភ័ស្តុតាងដែលទទួលបានតាំងពីមានសេចក្តីសម្រេចអំពីយុត្តាធិការ បានបញ្ជាក់ថា ក្នុងនាមជាមេបញ្ជាការកងពលធំ១៦៤ និងជាមេបញ្ជាការកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[21] មាស មុត

---

[16] **D48** សេចក្តីសម្រេចស្តីពីយុត្តាធិការបុគ្គល និងគោលនយោបាយស៊ើបសួរទាក់ទងនឹងជនសង្ស័យ មាស មុត, ២ ឧសភា ឆ្នាំ២០១២, ត្រង់កថាខណ្ឌ១៣។

[17] ដដែលដូចខាងលើ, ត្រង់កថាខណ្ឌ១២-១៥, ២៧ និងការសម្រេចបញ្ចប់លើសេចក្តីសម្រេចនេះ។

[18] ដដែលដូចខាងលើ, ត្រង់កថាខណ្ឌ១៦-២៣។

[19] ដដែលដូចខាងលើ, ត្រង់កថាខណ្ឌ២៤-២៧។

[20] ដដែលដូចខាងលើ, ត្រង់កថាខណ្ឌ២៨។

[21] **D54/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A9។

មានសិទ្ធិអំណាចទៅលើកម្លាំងកងពលធំ១៦៤ទាំងអស់ ព្រមទាំងការទទួលខុសត្រូវចំពោះទឹក ដី និងកោះរបស់កម្ពុជា[22]។ គាត់ត្រូវបានចាត់តាំងឲ្យកាន់មុខតំណែងយោធាកំពូលនេះ ក្នុងឆ្នាំ១៩៧៥ ដោយ ប៉ុល ពត ក្នុងសម័យប្រជុំដ៏ធំមួយដែលបានធ្វើឡើងនៅស្តាតអូឡាំពិក និងដែលមានការចូលរួមដោយកងពលធំ និងកងវរៈសេនាធំយោធាជាច្រើន ព្រមទាំងពីសមាជិកគណៈកម្មាធិការមជ្ឈិមបកក[23]។ ភស្តុតាងក៏បានអះអាងផងដែរពីមុខតំណែងរបស់ មាស មុត ជាប្រធានគណៈកម្មាធិការកំពង់សោម ដែលផ្តល់ឲ្យគាត់នូវសិទ្ធិអំណាចរដ្ឋបាលលើតំបន់នេះទាំងមូល និងសហករណ៍[24]។

១១. មាស មុត បានប្រើសិទ្ធិអំណាចរបស់គាត់ទៅលើកងពលធំ១៦៤ តាមរយៈ *ក្នុងចំណោមកិច្ចការផ្សេងៗទៀត* ការធ្វើជាអធិបតីក្នុងកិច្ចប្រជុំទៀងទាត់នានាជាមួយមេបញ្ជាការកងវរៈសេនាតូច និងកងវរៈសេនាធំ[25] ការត្រួតពិនិត្យកងទ័ពដែលឈរជើងនៅតាមកោះនានាដូចជា កោះប៉ូឡូវ៉ៃ កោះរ៉ុង និងកោះតាង[26] ការតាមដាន/ការទទួលរបាយការណ៍ពីមេបញ្ជាការថ្នាក់ក្រោមបង្គាប់របស់គាត់[27] ការដឹកនាំអនុវត្ត និងការឃ្លាំមើលវគ្គអប់រំបណ្តុះបណ្តាល[28] និងការចាត់តាំងថ្នាក់ក្រោមបង្គាប់ឲ្យ

---

[22] **D54/53** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A25។ **D54/35.1** សម្ភាសន៍ជាមួយ ប្រាក់ សុខា ត្រង់ ERN ជាភាសាអង់គ្លេស 00971211។ **D54/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A1។ **D54/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A18។ **D54/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុល សុង ត្រង់ A16។ **D59/1/1.11a** សម្ភាសន៍ជាមួយ ហៀង រ៉េត ត្រង់ ERN 00974134។ **D54.10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ី រ៉េត ត្រង់ A12។ **D54/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A1។ **D54/24** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A16-A20។

[23] **D54/50** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A25-A26។ **D54/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A1-A7; **D54/16/1R** កំណត់ហេតុស្តាប់ចម្លើយសាក្សីតតិយជន (David Kattenburg) ជាមួយ មាស មុត។

[24] **D54/47** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A28។ **D54/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ីម នី ត្រង់ A10-A11។ **D59/1/1.12** សម្ភាសន៍ជាមួយ ណុប ហាល ត្រង់ ERN 00968422។ **D54/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A11, A15។ **D59/1/4.25** កំណត់ហេតុស្តាប់ចម្លើយ ឡុង លី ត្រង់ ERN 00970714។ **D1.3.13.8** កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ត្រង់ ERN 00217560។

[25] **D54/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុល សុង ត្រង់ A14-A15។ **D54/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ីម នី ត្រង់ A5-A6។ សូមមើលផងដែរ **D56/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ត្រង់ A3។ **D54.10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ី រ៉េត ត្រង់ A12-A13 និង **D54/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឈឿន ត្រង់ A40។

[26] **D59/1/1.8a** សម្ភាសន៍ជាមួយ ព្រំ សារ៉េត ត្រង់ ERN 00974225; **D59/1/1.9a** សម្ភាសន៍ជាមួយ ឡាយ ប៊ុនហាក់ ត្រង់ ERN 00963744។

[27] **D54/47** សម្ភាសន៍ជាមួយ អែម ស៊ុន ត្រង់ A48-A49; **D54/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A22, A26, A32; **D54/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A48; **D54.10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ី រ៉េត ត្រង់ A22; **D59/1/1.12** កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ត្រង់ 00968421-22; **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A19។

[28] **D54/17** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន (*Say Born*) ត្រង់ A8-A13។ **D54/33** កំណត់ហេតុនៃការស្តាប់ ចម្លើយសាក្សី អ៊ឹង ឈឿន ត្រង់ A15-A18។ សូមមើលផងដែរ **D1.3.13.13** សម្ភាសន៍ជាមួយ ទូច ស៊ូលី ត្រង់ ERN 00217574។ **D54.10**

កាន់មុខតំណែងថ្មី[29]។ ភ័ស្តុតាងបង្ហាញថា បញ្ជារបស់ មាស មុត ត្រូវបានគេយកទៅអនុវត្តក្នុងរបៀបមួយប្រកបដោយវិន័យយ៉ាងតឹងរ៉ឹង[30]។ គាត់មានសិទ្ធិអំណាចដាក់វិន័យទៅលើមេបញ្ជាការក្រោមបង្គាប់របស់គាត់ រួមទាំងការសម្លាប់ដែលបានធ្វើឡើងដោយពុំចាំបាច់មានការយល់ព្រមជាមុនពីគាត់[31]។ សូម្បីតែនៅក្រោយការចាត់តាំងគាត់ឡើងវិញមក ភ្នំពេញ/ភូមិភាគបូព៌ា នៅក្នុងឆ្នាំ ១៩៧៨ ក៏ដោយ ក៏គាត់នៅតែបន្តបញ្ជាកងពលធំ១៦៤ ដដែល[32]។

១២. មាស មុត បានប្រើសិទ្ធិអំណាចផ្តាច់មុខ ទាក់ទងនឹងចលនាកងកម្លាំងកងទ័ពជើងទឹក និងកងនាវាទាំងអស់[33]។ ក្នុងចំណោមកិច្ចការផ្សេងទៀត មេបញ្ជាការអង្គភាពកងទ័ពជើងទឹកគ្មានសិទ្ធិអំណាចធ្វើការសម្រេចចិត្តណាមួយ អំពីជោគវាសនារបស់ទូកជនស៊ីវិលដែលគេចាប់បានឡើយ និងអាចបានត្រឹមតែធ្វើតាមបញ្ជារបស់ទីបញ្ជាការកងពលធំ១៦៤[34] តែប៉ុណ្ណោះ។

១៣. ក្នុងនាមជាមេបញ្ជាការកងពលធំមជ្ឈិមបក្ស មាស មុត បានរាយការណ៍ដោយផ្ទាល់ទៅសមាជិកមជ្ឈិមបក្សរួមទាំងសុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិនៃកម្ពុជាប្រជាធិបតេយ្យ។ របាយការណ៍បន្ថែមដែលមិនបានលើកយោងក្នុងសេចក្តីសម្រេចអំពីយុត្តាធិការ បង្ហាញអំពីការប្រាស្រ័យទាក់ទងរបស់ មាស មុត ជាមួយមជ្ឈិមបក្សស្តីពី៖ សកម្មភាពខ្មាំង[35] ការឈ្លបយកការណ៍និងការចាប់ខ្លួន[36] រួមទាំងការទាញយកចម្លើយសារភាពពីអ្នកទោសកុមារ[37] ការដាក់វិន័យ/ការហ្វឹកហ្វឺន

---

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ី រ៉េត ត្រង់ A12។ **D54/11** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ី រ៉េត ត្រង់ A28។ **D59/1/1.8a** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ ត្រង់ ERN 00974185។

[29] **D4.1.801** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ត្រង់ A27។ **D59/1/1.7a** កំណត់ហេតុស្តាប់ចម្លើយ ម៉ា ឈឿន ត្រង់ ERN 00969948។

[30] **D54/47** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A48 និង A49; **D54/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A14-A18។ **D54/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A42 និង A44-A46។ **D56/28** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡុន ត្រង់ A14។ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A24-A25។

[31] **D59/1/1.11a** សម្ភាសន៍ជាមួយ ហៀង រ៉េត ត្រង់ ERN 00974135-36។

[32] **D59/1/1.11a** សម្ភាសន៍ជាមួយ ហៀង រ៉េត ត្រង់ ERN 00974119-20។ **D59/1/1.8a** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ ERN 00974227-8។

[33] **D54.10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ី រ៉េត ត្រង់ A25-A26។

[34] **D54/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឈឿន ត្រង់ A21-23។

[35] **D1.3.34.14** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ តុលា ១៩៧៦ មានចំណងជើងថា "បង មុត សូមបងជ្រាប"។

[36] **D1.3.14.2** ទូរលេខសម្ងាត់របស់យោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៣ កក្កដា ១៩៧៧ មានចំណងជើងថា "ចំពោះ សមមិត្តបងមុត ជាទីស្នេហា"។ **D1.3.34.15** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ តុលា ១៩៧៦ មានចំណងជើងថា "ចំពោះបង មុត ជាទីនឹករលឹក និងស្នេហា" **D1.3.12.3** របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២២ កុម្ភៈ ១៩៧៦ មានចំណងជើងថា "ជូនបង ៨៩"។ **D.3.14.1** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១១ មិថុនា ១៩៧៦ មានចំណងជើងថា "ចំពោះបង ៨៩ ជាទីគោរព"។

[37] **D1.3.34.12** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៧ កញ្ញា ១៩៧៦ មានចំណងជើងថា "ជូនចំពោះបង មុត"។

បុគ្គលិក[38] ការប៉ះទង្គិចគ្នាជាមួយកងកម្លាំងថៃ[39] អាមេរិកកាំង[40] និងវៀតណាម[41] លក្ខខណ្ឌផ្នែកធនធាន និងភ័ស្តុភារ[42] ប្រតិបត្តិការរបស់មន្ទីរពេទ្យកងពលធំ១៦៤ និងចំនួនអ្នកស្លាប់នៅក្នុងមន្ទីរពេលនេះ[43] និងការប្តេជ្ញាចិត្តរបស់គាត់ក្នុងគោលនយោបាយរបស់បក្ស នៅក្នុង "ការបោសសម្អាតខ្មាំង"[44]។ ភ័ស្តុតាងបន្ថែម ក៏ត្រូវបានប្រមូលផងដែរទាក់ទងនឹងការចូលរួមដោយផ្ទាល់របស់ មាស មុត ក្នុងកិច្ចប្រជុំនានារបស់អគ្គសេនាធិការ[45]។

១៤. ក្នុងឋានៈជាមេបញ្ជាការកងពលរបស់មជ្ឈិមបក្ស មាស មុត មានសិទ្ធិអំណាចកម្រិតខ្ពស់ជាងមេបញ្ជាការកងពលនានានៅតាមភូមិភាគ និងមានអំណាចនៅក្នុងការដាក់ទិសដៅដល់កងកម្លាំងនានាតាមតំបន់[46]។ ភស្តុតាងដែលប្រមូលបានថ្មីៗ មានរៀបរាប់ពីការបញ្ជូន មាស មុត ជាមួយនឹងកងកម្លាំងមួយចំនួនរបស់កងពលលេខ១៦៤ ទៅកាន់ភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨ ដែលនៅទីនោះគាត់បានធ្វើការសម្របសម្រួលជាមួយនឹងអង្គភាពយោធាដទៃទៀតនៃកម្ពុជាប្រជាធិបតេយ្យ នៅក្នុងជម្លោះប្រដាប់អាវុធជាមួយនឹងកងកម្លាំងវៀតណាម[47]។ នៅខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងរបស់ មាស មុត បានវាយប្រហារទៅលើអង្គភាពនានានៃកម្ពុជាប្រជាធិបតេយ្យ ដែលបានដកថយពីការប្រយុទ្ធគ្នា[48]។ ភស្តុតាងក៏បានលើកឡើងផងដែរថា ជាការបន្ថែមទៅលើតួនាទីដែលមានពីមុន

---

[38] **D1.3.14.2** ទូរលេខសម្ងាត់របស់យោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៣ កក្កដា ១៩៧៧ មានចំណងជើងថា "ជូន សមមិត្តបង មុត ជាទីស្នេហា"។ **D1.3.34.13** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៧ តុលា ១៩៧៦ មានចំណងជើងថា "បង មុត សូមបងជ្រាប"។

[39] **D1.3.34.27** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៣ កញ្ញា ១៩៧៧ មានចំណងជើងថា "សភាពការណ៍តាមព្រំដែន"។

[40] **D1.3.12.2** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៣ សីហា ១៩៧៦ មានចំណងជើងថា "ជូនចំពោះបង៨៩ ជាទីគោរព"។

[41] **D1.3.34.60** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៣១ ធ្នូ ១៩៧៧ មានចំណងជើងថា "ជូនមន្ទីរ៨៧០ ជាទីគោរព"។

[42] **D1.3.34.13** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៧ តុលា ១៩៧៦ មានចំណងជើងថា "បង មុត សូមបងជ្រាប"។ **D4.1.1020** របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២០ កុម្ភៈ ១៩៧៦ មានចំណងជើងថា "ជូនបង៨៩ ជាទីគោរព"។ **D1.3.34.14** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ តុលា ១៩៧៦ មានចំណងជើងថា "បង មុត សូមបងជ្រាប"។

[43] **D4.1.1020** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២០ កុម្ភៈ ១៩៧៦ មានចំណងជើងថា "ជូនបង៨៩ ជាទីគោរព"។

[44] **D1.3.34.60** ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៣១ ធ្នូ ១៩៧៧ មានចំណងជើងថា "ជូនមន្ទីរ៨៧០ ជាទីគោរព"។

[45] **D56/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ត្រង់ A3។

[46] **D54/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A4។ **D54/54** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A5, A6 និង A10។ **D54/50** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A6។ សូមអានផងដែរ **D59/1/4.23** បទសម្ភាសន៍ជាមួយ អ៊ូ សារ៉ាន់ ត្រង់ ERN 00978675-6។

[47] **D56/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ត្រង់ A3។ **D56/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ត្រង់ A17។ **D54/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុល សុង ត្រង់ A15។ **D59/1/4.23** បទសម្ភាសន៍ជាមួយ អ៊ូ សារ៉ាន់ ត្រង់ ERN 00978674-5។ **D54/50** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A6។

[48] **D54/50** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A5, សូមអាន A6 ផងដែរ។

ជាមេដឹកនាំជាន់ខ្ពស់មួយរូបតាមឋានុក្រមនៃកងទ័ពបដិវត្តកម្ពុជា មាស មុត ជាអនុបញ្ជាការរបស់ សុន សេន នៅក្នុងប្រតិបត្តិការនានានៅភូមិភាគបូព៌ា[49]។

១៥. ភស្តុតាងបន្ថែមទៀតដែលបានប្រមូល បានបង្ហាញអំពីភាពចាស់វស្សារបស់ មាស មុត ក្នុងឋានៈជាមេបញ្ជាការកងពលលេខ៣ (មុនកងពលលេខ១៦៤) ដែលនៅក្នុងតួនាទីនោះ គាត់មានការទទួលខុសត្រូវក្នុងការបញ្ជាកងកម្លាំងនានាធ្វើការវាយប្រហារទីក្រុងភ្នំពេញ នៅដើមឆ្នាំ១៩៧៥[50]។ ភស្តុតាងនេះគឺមានការពាក់ព័ន្ធ ដោយហេតុថាវាបង្ហាញពីរយៈពេលនៃសិទ្ធិអំណាចរបស់គាត់ ក្នុងឋានៈជាមេបញ្ជាការយោធាជាន់ខ្ពស់មួយរូបរបស់ខ្មែរក្រហម។

១៦. ភស្តុតាងដែលមានថ្មីៗក៏បានបញ្ជាក់ផងដែរថា មាស មុត មានសិទ្ធិអំណាចក្នុងការបញ្ជាឲ្យមានការរៀបអាពាហ៍ពិពាហ៍នៅក្នុងតំបន់ប្រតិបត្តិការណ៍នានារបស់គាត់ ហើយថា អាពាហ៍ពិពាហ៍មួយចំនួនដែលបានដំណើរការដោយកងពលលេខ១៦៤ គឺត្រូវបានធ្វើឡើងដោយបង្ខំ[51]។

## *II.ខ. ភស្តុតាងថ្មីស្តីពីការចូលរួមចំណែករបស់ មាស មុត នៅក្នុង សហឧក្រិដ្ឋកម្មរួម/ការចូលរួមប្រព្រឹត្តបទឧក្រិដ្ឋ*

១៧. ភស្តុតាងដែលបានប្រមូលចាប់តាំងពីសេចក្តីសម្រេចលើយុត្តាធិការ បានបញ្ជាក់ពីអង្គហេតុពិតដែលថា ការបោសសម្អាតបានកើតឡើងយ៉ាងច្រើននៅក្នុងកងពលលេខ១៦៤[52]។ ពួកយុទ្ធជន និងពួកមេបញ្ជាការនៅក្នុងកងពលលេខ១៦៤ ត្រូវបានចាប់ ហើយបាត់ខ្លួនជារៀងរហូត ដោយសារពួកនោះត្រូវបានចោទប្រកាន់ថាជាជនក្បត់ ឬជាភ្នាក់ងារសេអ៊ីអា ឬកាហ្សេបេ។ សមាជិកគ្រួសាររបស់ពួកជនរងគ្រោះក៏ត្រូវបានដកចេញដែរ[53]។ មាស មុត បានដឹងឮ និងបានចូលរួម

---

[49] **D59/1/1.8a** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ ត្រង់ ERN 00974226-7។ សូមអានផងដែរ **D59/1/1.9a** បទសម្ភាសន៍ជាមួយ ឡាយ ប៊ុនហាក់ ត្រង់ ERN 00963745, និង **D59/1/1.11a** បទសម្ភាសន៍ជាមួយ ហៀង រ៉េត ត្រង់ ERN 00974120។

[50] **D54/46** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A31, A33-35, A38 និង A39។ **D54/43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង *(Lon Seng)* ត្រង់ A4, A6-A7។ សូមអានផងដែរ **D54/35.1** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ត្រង់ ERN 00971209, និង **D59/1/4.23** បទសម្ភាសន៍ជាមួយ អ៊ូ សារ៉ាន់ ត្រង់ ERN 00978666។

[51] **D59/1/1.7a** បទសម្ភាសន៍ជាមួយ ម៉ា ឈឿន ត្រង់ ERN 00969949-50។ **D56/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ត្រង់ A3-A6។

[52] **D59/1/4.23** បទសម្ភាសន៍ជាមួយ អ៊ូ សារ៉ាន់ ត្រង់ ERN 00978676-7។ សូមអាន, ជាឧទាហរណ៍ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A33 - A36។ **D54/27** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A1-A6។

[53] **D54/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុល សុង ត្រង់ A3-A4។

ចំណែកនៅក្នុងការ បោសសម្អាតទាំងនេះ[54]។ គាត់មានសិទ្ធិអំណាចនៅក្នុងការចាប់ខ្លួនពួកយុទ្ធជន និងអ្នកដទៃទៀត ដែលស្ថិតនៅក្រោមតំបន់នៃការទទួលខុសត្រូវរបស់គាត់[55]។ គាត់បានធ្វើការប្រកាសពាក់ព័ន្ធនឹង ការចាប់ខ្លួនពួកមេបញ្ជាការនៅក្នុងការប្រជុំនានាជាមួយអ្នកនៅក្រោមបង្គាប់របស់គាត់ ដែលការ ចាប់ខ្លួននេះក្រោយមកត្រូវបានធ្វើចុះមកក្រោមតាមឋានានុក្រមកងពល[56]។ ក្នុងចំណោមអ្នកដែលត្រូវបានចាប់ខ្លួនដោយសារមានបញ្ជាដោយ មាស មុត គឺមានអនុរបស់គាត់ ឈ្មោះ ចាន់ Chan (ឆាន Chhan)[57] និងឈ្មោះ ឡូញ Lonh ដែលជាសមាជិកមួយរូបក្នុងគណៈកម្មាធិការកំពង់សោម[58]។ ភស្តុតាងក៏បានបញ្ជាក់ផងដែរថា នៅពេលដែលពួកកម្មាភិបាលដែលមានឋានៈខ្ពស់ៗនៃកងពលលេខ១៦៤ ត្រូវបានចាប់ខ្លួន អ្នកនៅក្រោមបង្គាប់របស់ពួកគេចំនួនរាប់សិបនាក់ ត្រូវបានដាក់ក្នុងជំរុំពលកម្មដោយបង្ខំដើម្បីធ្វើការអប់រំសារជាថ្មី[59]។ ភស្តុតាងស្តីពីការចូលរួមចំណែករបស់ មាស មុត នៅក្នុងការបោសសម្អាតបុគ្គលិកយោធាកងពលលេខ១៦៤ ត្រូវបានគេ មើលឃើញ ដោយមានសេសសល់ចម្លើយសារភាពនៅ ស-២១ ដោយមានចំណារផ្សេងៗដែលជា ការបញ្ជាក់បានថា មតិ និង ការចាត់ការបន្តទៀតរបស់គាត់ ត្រូវបានគេស្វែងរក ទាក់ទងទៅនឹង ការបន្តការស៊ើបអង្កេតទៅលើពួកកម្មាភិបាលនានាដែលនៅក្រោមបង្គាប់របស់គាត់[60]។

១៨. ភស្តុតាងដែលបានប្រមូលចាប់តាំងពីសេចក្តីសម្រេចលើយុត្តាធិការក៏បានបញ្ជាក់ផងដែរ ពីការចូលរួមចំណែកយ៉ាងច្រើនរបស់ មាស មុត នៅក្នុងការបោសសម្អាតកងកម្លាំងភូមិភាគបូព៌ាដែលនៅក្នុងកងពលលេខ១៦៤ ជារួមមាន៖ ការចូលរួមរបស់គាត់នៅក្នុងការប្រជុំមួយដែលពួកមេដឹកនាំ

---

[54] **D54/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុល សុង ត្រង់ A6, A8។ សូមអានផងដែរ **D4.1.810** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ត្រង់ A35, និង **D54/11** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឺ រ៉េត ត្រង់ A19-A22។

[55] **D54/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុល សុង ត្រង់ A16- A17។ **D54/54** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A7។ សូមអានផងដែរ **D54/37** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ត្រង់ A6-A23។

[56] **D54/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុល សុង ត្រង់ A5-A9។

[57] **D54.10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឺ រ៉េត ត្រង់ A7-A8។ **D59/1/1.12** បទសម្ភាសន៍ជាមួយ ណុប ហាល ត្រង់ ERN 00968418។

[58] **D54/53** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A22-24, A26-A29។ **D54/54** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A7។ **D54/31** កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សី ស៊ឹម នី ត្រង់ A10។

[59] **D54/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ត្រង់ A14។ **D54/35** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ត្រង់ A14, A17។ **D54/36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ត្រង់ A1-A2។

[60] **D1.3.17.6** Stephen Heder and Brian Tittemore *បេក្ខជនចំនួនប្រាំពីរនាក់ដែលត្រូវកាត់ទោស៖ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម,* (ការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាម, មហាវិទ្យាល័យច្បាប់វ៉ាស៊ីងតោន, សាកលវិទ្យាល័យអាមេរិកកាំង និងសម្ព័ន្ធភាពដើម្បីយុត្តិធម៌អន្តរជាតិ) ត្រង់ ERN 00393619។ **D1.3.18.1** ចម្លើយសារភាពស-២១ របស់ ហង់ ឌឿន *ហៅ* ឌឹម, ចុះថ្ងៃទី១៥ ឧសភា ១៩៧៧។ **D1.3.18.3** S21 ចម្លើយសារភាពស-២១ របស់ គុន ឌឿន ចុះថ្ងៃទី២១ កក្កដា ១៩៧៧។ **D4.1.1066** ចម្លើយសារភាពស-២១ របស់ ប៉ែន ហម ចុះថ្ងៃទី២៤ ឧសភា ១៩៧៧។

បកក បានប្រកាសពីសេចក្តីសម្រេចមួយដើម្បីធ្វើការបោសសម្អាតភូមិភាគបូព៌ា[61] ការប្រកាសរបស់គាត់នៅក្នុងកិច្ចប្រជុំពិសេសមួយនៃកងពលលេខ១៦៤ ដែលថា ពួកយុទ្ធជនភូមិភាគបូព៌ា "គឺជាយោធាដែលមានសមាសភាពមិនល្អ ត្រូវតែដកចេញឲ្យដាច់ពីកងពល"[62], ការចាប់ខ្លួនអនុរបស់គាត់ឈ្មោះ ឌឹម[63] ពួកបញ្ជាការ និងពួកយុទ្ធជន នៃកងពលលេខ១៦៤ ដែលមានប្រភពមកពីភូមិភាគបូព៌ា[64] បញ្ជារបស់ មាស មុត ឲ្យគេបញ្ជូនពួកទ័ពភូមិភាគបូព៌ាមួយចំនួនធំទៅកាន់ជំរុំពលកម្មដោយបង្ខំ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលលេខ១៦៤[65]។

១៩. ភស្តុតាងដែលបានប្រមូលចាប់តាំងពីសេចក្តីសម្រេចលើយុត្តាធិការបានបញ្ជាក់ថា វត្តឥន្ទញ្ញាណ គឺជាមន្ទីរសន្តិសុខរបស់កងពលលេខ១៦៤[66] ដែលអ្នកទោសមានរួមទាំងពួកយុទ្ធជនកងពលលេខ ១៦៤ ផង[67]។ ភស្តុតាងបានលើកឡើងពីការចូលរួមរបស់ មាស មុត នៅឯទីកន្លែងឧក្រិដ្ឋកម្មនេះ[68]។ ភស្តុតាងថ្មីក៏បានបង្ហាញផងដែរថា មាស មុត មានសិទ្ធិអំណាចទៅលើមន្ទីរសន្តិសុខទឹកសាប ដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើការឃុំឃាំង ទាំងពួកបុគ្គលិកយោធានៃកងពលលេខ ១៦៤ និងទាំងជនស៊ីវិល ដែលគេបានចាត់ទុកថាមានទោសធ្ងន់[69]។ ពួកអ្នកដែលត្រូវបានបញ្ជូនទៅកាន់ទឹកសាបគឺ "មិនដែលរស់ទេ"[70]។ អ្នកទោសខ្លះត្រូវបានបញ្ជូនពីទឹកសាបទៅកាន់ភ្នំពេញ

---

[61] **D4.1.408** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួក រិន *ហៅ* សុខ (កែតម្រូវ) ត្រង់ ERN 00766393។

[62] **D54/44** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ត្រង់ A19 និង A23-A26 និង A28។ **D54/43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ត្រង់ A1-A4។

[63] **D54/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A13។ **D54/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A21។ **D54/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡុន ត្រង់ A19-A20។ **D54/39** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន វី ត្រង់ A10។ **D54/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុល សុង ត្រង់ A12-14។

[64] **D54/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុល សុង ត្រង់ A17-A18។ **D54/24.1** បទសម្ភាសន៍ជាមួយ ប៉ាក សុខ ត្រង់ ERN 00978576 និង ERN 00978580។ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A33, A35។

[65] **D54/44** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ត្រង់ A6, A19។ **D54/39** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន វី ត្រង់A2-A5។

[66] **D54/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A44, A51 និង A52។ **D54/32** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន ត្រង់ ERN 00217562។ និង **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A6។

[67] **D54/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A52។ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A23-A25។

[68] **D54/32** កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សី ស៊ឹម នី ត្រង់ A34-A37។

[69] **D54/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ត្រង់ A10-A12។ **D54/36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ត្រង់ A22។ **D54/24.1** បទសម្ភាសន៍ជាមួយ ប៉ាក សុខ ត្រង់ ERN 00978576 និង 00978579។ **D54/27** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A9-A1។

[70] **D54/36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ត្រង់ A7។

(ទំនងជា ស-២១)[71]។ ពួកជនរងគ្រោះនៅទឹកសាប រួមមានជនជាតិពន្ធុខ្មែរក្រោមដែលត្រូវបានចាប់ខ្លួន ដោយសារត្រូវបានគេគិតថា មានពាក់ព័ន្ធជាមួយនឹងវៀតណាម[72]។

២០. ភស្តុតាងថ្មីៗក៏បានបញ្ជាក់ផងដែរថា ស្ទឹងហាវ ត្រូវបានប្រើប្រាស់ដោយកងពលលេខ១៦៤ ធ្វើជាកន្លែងលត់ដំ/ពលកម្មដោយបង្ខំ ហើយពួកអ្នកទោសក៏ត្រូវបានសម្លាប់នៅកន្លែងនេះផងដែរ[73]។ មាស មុត បានទៅធ្វើទស្សនកិច្ចនៅទីកន្លែងនេះ[74] ហើយបានធ្វើការប្រជុំនានានៅផ្ទះរបស់គាត់ដែលចូលរួមដោយពួកបញ្ជាការស្ទឹងហាវ[75]។ គាត់ក៏បានធ្វើជាអធិបតីក្នុងការប្រជុំមួយដ៏ធំផងដែរ នៅក្នុងឆ្នាំ១៩៧៧ ដែលបានធ្វើឡើងនៅក្នុងទស្សនៈវិស័យនៃស្ទឹងហាវ។ នៅក្នុងអង្គប្រជុំនេះ គាត់បានប្រកាសពីអត្ថិភាពនៃ បកក ហើយ ប៉ុល ពត គឺជាមេដឹកនាំ ហើយបានថ្លែងថា ពួកអ្នកដែលក្បត់បក្ស រួមទាំងអ្នកដែលគេសន្មតថាជាភ្នាក់ងារ សេអ៊ីអា និងកាហ្សេបេ ត្រូវតែ "សម្រិតសម្រាំងចេញ" និង ត្រូវទុកម្ដុំ[76]។ ដោយឡែក គាត់បានប្រកាសថា ពួកសមាជិកគណៈតំបន់៣៧ អនុរបស់គាត់ឈ្មោះ ឌឹម (យោងនៅខាងលើ), ជ័យ សួន (រដ្ឋមន្ត្រីក្រសួងកសិកម្មនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានសម្លាប់នៅ ស-២១) និង សោ ភឹម (លេខាភូមិភាគបូព៌ា ដែលត្រូវបានបោសសម្អាតតាមបញ្ជារបស់មជ្ឈិមបក្ស) គឺជាពួក ក្បត់[77]។

២១. ភស្តុតាងដែលមានថ្មីៗបានបញ្ជាក់ថា មាស មុត បានណែនាំកងម៉ារីននៃកងពលលេខ១៦៤ ឲ្យចាប់ឃាត់ទូកប្រជាជនស៊ីវិលនៅសមុទ្រទុក ហើយរាយការណ៍ទៅខាងលើ[78]។ ដោយអនុវត្តតាមបញ្ជារបស់គាត់ កងកម្លាំងនៃកងពលលេខ១៦៤ បានធ្វើការចាប់ខ្លួន បានឃុំឃាំង និងបានសម្លាប់ពួកអ្នកនេសាទថៃ "គេញ" វៀតណាម និងជនបរទេសផ្សេងៗទៀតដែលនៅសមុទ្រអស់ជាច្រើននាក់[79]។ មាស មុត បានផ្ដល់ការណែនាំថា "ពួកភ្នាក់ងារចារកម្ម" ដែលបានឃាត់ទុក ត្រូវតែចាប់

---

[71] **D54/20** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ សោម ត្រង់ A12។

[72] **D54/36** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ សុខា ត្រង់ A6, A10។

[73] **D54/36** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ សុខា ត្រង់ A22, A24-A28, A32 និង A34។

[74] **D1.3.13.8** បទសម្ភាសន៍ជាមួយ ប៉ែន សារិន ត្រង់ ERN 00217560។ **D54/77** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុយ ញឹក ត្រង់ A52។

[75] **D54/31** កំណត់ហេតុនៃការស្ដាប់ចម្លើយ សាក្សី ស៊ឹម នី ត្រង់ A6។

[76] **D54/13** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រេស មាន ត្រង់ A4-5, A10-A11។

[77] **D54/12** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រេស មាន ត្រង់ A23, A25-A32។ **D54/13** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រេស មាន ត្រង់ A2, A13។

[78] **D59/1/1.8a** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ ត្រង់ ERN 00974221។

[79] **D54/8** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌុល សុង ត្រង់ A41-A49។ **D59/1/1.11a** បទសម្ភាសន៍ជាមួយ ហៀង វ៉េត ត្រង់ ERN 00974107។ **D54/33** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹង ឆុន ត្រង់ A20។ សូមអានផងដែរ **D54/34** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹង ឆុន ត្រង់ A1-A5, A12, A15-A19, A27-A31។ **D54/11** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ី វ៉េត ត្រង់ A3-A9។ **D54/25** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A20, A22។ **D59/1/4.23** បទសម្ភាសន៍ជាមួយ អ៊ី

ខ្លួនបញ្ជូនទៅកាន់ ស-២១[80]។ ដោយឡែក គាត់ក៏បានបញ្ជាផងដែរឲ្យមានការប្រហារជីវិតពួកអ្នកដែលគេបានចាប់ទុក[81]។ អ្នកដែលគេចាប់ឃាត់ដែលមិនទាន់បានសម្លាប់ភ្លាមៗ ត្រូវបានឃុំឃាំង និងបញ្ជូនទៅក្រោមការត្រួតពិនិត្យរបស់បញ្ជាការដ្ឋានកងពលលេខ ១៦៤[82]។ ក្រោយមក ពួកថៃដែលគេបានចាប់ឃាត់មួយចំនួនត្រូវជាប់ឃុំ និងបង្ខំឲ្យធ្វើការនៅលើដីគោក[83] ខណៈដែលពួកវៀតណាមត្រូវគេសម្លាប់ចោលទាំងអស់តាមបញ្ជារបស់ មាស មុត[84]។ ប្រជាជនស៊ីវិលថៃ និងវៀតណាម ដែលកងកម្លាំងនៃកងពលលេខ១៦៤ បានសម្លាប់ត្រូវបានគេប៉ាន់ប្រមាណថាមានចំនួនរាប់ពាន់នាក់[85]។ មាស មុត បានរាយការណ៍ពីការចាប់ឃាត់ទូករបស់ប្រជាជនស៊ីវិលថៃ និងវៀតណាម ទៅមជ្ឈិមបក្ស [86]។ យោងតាមភស្តុតាងដែលមានថ្មីៗ កងកម្លាំងរបស់កងពលលេខ ១៦៤ ក្រោមបញ្ជារបស់ មាស មុត ក៏បានទទួលពួកនេសាទថៃ និងជនស៊ីវិលវៀតណាម ដែលកងកម្លាំងកងពលលេខ១ របស់ភូមិភាគបស្ចិមបានចាប់ឃាត់ យកទៅគ្រប់គ្រងផងដែរ[87]។

២២. ភស្តុតាងដែលប្រមូលបានថ្មីៗបង្ហាញថា មាស មុត បានចេញបញ្ជាមួយឲ្យសម្លាប់ទាហានម៉ារីនអាមេរិកកាំង ២(ពីរ)នាក់ ដែលគេបានចាប់ឃាត់បន្ទាប់ពីមានការប្រយុទ្ធគ្នាមួយដែលបានកើតឡើងនៅក្រោយកងកម្លាំងកងពលលេខ៣ បានឃាត់កប៉ាល់ *ម៉ាយ៉ាហ្គេស* របស់អាមេរិកកាំង[88]។

២៣. ភស្តុតាងដែលមានថ្មីៗក៏បានបញ្ជាក់ផងដែរថា ទីកន្លែងពលកម្មដោយបង្ខំ/អប់រំសារជាថ្មីមួយចំនួនត្រូវបានប្រតិបត្តិការដោយកងពលលេខ១៦៤ ឬដោយប្រធានសហករណ៍ ក្រោមបញ្ជារបស់កងពល។ ទីកន្លែងទាំងនេះមានទីតាំងនៅ៖ ក) ឃុំបិទត្រង់/ចំណោទរាម ខ) តំបន់កងកេង និង គ) ឃុំរាម។ តំបន់ទាំងនេះត្រូវបានពិភាក្សាយ៉ាងសង្ខេបដូចខាងក្រោម៖

---

សាវ៉ាន់ ត្រង់ ERN 00978678។ **D54/24.1** បទសម្ភាសន៍ជាមួយ ប៉ាក សុខ ត្រង់ ERN 00978573 និង ERN 00978576-77។ និង **D1.3.13.8** បទសម្ភាសន៍ជាមួយ ប៉ែន សារិន ត្រង់ ERN 00217561-2។

[80] **D59/1/1.8a** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សាវ៉ាត់ ត្រង់ ERN 00974222។

[81] **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A1-A4។

[82] **D54/34** កំណត់ ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ត្រង់ A21, A32។ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A6, A10។ **D54/24.1** បទសម្ភាសន៍ជាមួយ ប៉ាក សុខ ត្រង់ ERN 00978573-74។

[83] **D54/24.1** បទសម្ភាសន៍ជាមួយ ប៉ាក សុខ ត្រង់ ERN 00978575។

[84] **D54/24.1** បទសម្ភាសន៍ជាមួយ ប៉ាក សុខ ត្រង់ ERN 00978576 និង ERN 00978578។

[85] **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A11។ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A11-A13 និង A23។

[86] **D54/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A13។ **D54/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A22។ **D4.1.1020** របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២០ កុម្ភៈ ១៩៧៦ ។

[87] **D54/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A18, A24 និង A35។ **D54/53** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A12 និង A16-A18។ **D54/54** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ត្រង់ A1។

[88] **D54/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម ស៊ុន ត្រង់ A34។

ក. មានការដ្ឋានពលកម្មដោយបង្ខំមួយចំនួននៅឃុំបិទត្រង់/ឃុំចំណោទរាម[89] ស្រុកព្រៃនប់[90] ។ ភស្តុតាងបានលើកឡើងថាមានប្រជាជនចំនួនរាប់រយនាក់[91] ត្រូវបានបញ្ជូនទៅកាន់ទីកន្លែងទាំងនេះ រួមមាន ពួកក្មេងៗ[92] ប្រជាជនថ្មី[93] និងពួកចាម[94]។ ពួកជនរងគ្រោះត្រូវបានគេបង្ខំឲ្យលើកទំនប់ និងធ្វើស្រែ និងដាំដំណាំផ្សេងៗ[95]។ ពួកគេត្រូវបានផ្តល់របបហូបចុកមិនគ្រប់គ្រាន់[96] ត្រូវបានវាយធ្វើបាប[97] និងត្រូវបានបង្ខំឲ្យធ្វើការជាច្រើនម៉ោង (ជាញឹកញាប់ រហូតដល់យប់ជ្រៅ)[98]។ ប្រជាជនខ្លះត្រូវបានស្លាប់ដោយសារជម្ងឺ[99]។ មានការបាត់ខ្លួនជាបន្តបន្ទាប់[100] នៃប្រជាជនផងដែរ[101] ដែលភាគច្រើនត្រូវបានគេរាយការណ៍

[89] **D54/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខិន ជុន ត្រង់ A9។ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A26-A29។

[90] **D5/1049/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី (Sam Vuthy) ត្រង់ ERN 00991850។

[91] **D54/18** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ត្រង់ A16។

[92] **D54/18** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ត្រង់ A10។

[93] **D5/1049/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី (Sam Vuthy) ត្រង់ ERN 00991850។ **D1050/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ណាប់ សូម៉ាល័យ (Nap Somalay) ត្រង់ ERN 00991870។ **D54/18** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ត្រង់ A18។ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A26-A29។

[94] **D5/1049/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី (Sam Vuthy)ត្រង់ ERN 00991851។

[95] **D5/1049/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី (Sam Vuthy) ត្រង់ ERN 00991850។ **D1050/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ត្រង់ ERN 00991870។ **D22/1998/1** របាយការណ៍ពីអង្គភាពជន រងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សារឿន ត្រង់ ERN 00541435។ **D54/35** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ត្រង់ A17។ **D54/18** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ត្រង់ A14។

[96] **D5/1049/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី (Sam Vuthy) ត្រង់ ERN 00991850។ **D1050/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ណាប់ សូម៉ាល័យ Nap Somalay ត្រង់ ERN 00991870។ **D22/1998/ 1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សារឿន ត្រង់ ERN 00541435។

[97] **D5/1049/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី (Sam Vuthy) ត្រង់ ERN 00991851។

[98] **D5/1049/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី (Sam Vuthy) ត្រង់ ERN 00991850។ **D1050/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ណាប់ សូម៉ាល័យ (Nap Somalay) ត្រង់ ERN 00991870។

[99] **D22/1998/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សារឿន ត្រង់ ERN 00541435។

[100] **D1050/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ណាប់ សូម៉ាល័យ (Nap Somalay) ត្រង់ ERN 00991871។ **D54/18** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ត្រង់ A15, A18។

[101] **D5/1049/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី (Sam Vuthy) ត្រង់ ERN 00991851។ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A26-A29។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ត្រង់ A18។

ថាត្រូវបានសម្លាប់នៅឃុំបិទត្រង់[102] និងនៅជិតចំការធូរេន (ត្រូវបានពិភាក្សានៅខាងក្រោម)[103]។ ប្រជាជន "ដែលបានបាត់ខ្លួន" ដោយសារមូលហេតុផ្សេងៗ រួមមាន ជម្ងឺ "ការខ្ជិលច្រអូស" និង មិនមានលទ្ធភាពអាចធ្វើពលកម្មបាន[104]។

ខ. ការដ្ឋានធ្វើពលកម្មដោយបង្ខំមួយចំនួន[105] បានដំណើរការការងារម៉ុជិតៗចំណតយន្តហោះកង កេង ដែលមានទីតាំងស្ថិតនៅក្នុងស្រុកព្រៃនប់ ខេត្តកំពង់សោម នៅក្បែរផ្លូវជាតិលេខ៤[106]។ ការដ្ឋានទាំងនេះត្រូវបានចាត់ចែងគ្រប់គ្រងដោយកងពលធំលេខ១៦៤ ដែលត្រួតពិនិត្យដោយ មាស មុត ផ្ទាល់[107]។ ហើយដែលត្រូវមើលពីលើដោយកងកម្លាំងនានាដែលត្រូវរាយការណ៍ជូនគាត់[108]។ ការដ្ឋានទាំងនេះត្រូវបានប្រើប្រាស់សម្រាប់អប់រំកែប្រែពួកយោធា[109](ក្នុងករណីខ្លះរហូតដល់កងវរៈសេនាតូចទាំងមូល[110] ក៏ដូចជាសម្រាប់ការបោសសំអាត ពួកយោធានៃភូមិភាគបូព៌ា[111]) ព្រមទាំងប្រជាជនស៊ីវិលមួយចំនួន[112]។ ជនទាំងឡាយដែលត្រូវគេបញ្ជូនទៅកាន់ការដ្ឋានទាំងនេះត្រូវបានគេចោទថាជា "សមាសភាពមិនល្អ"[113] ឬក៏ជា "អ្នកមិនស្តាប់បង្គាប់"[114]។ មានការដ្ឋានមួយក្នុង ចំណោមការដ្ឋាន

[102] **D11/371/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សួន ឌឿន (Suon Doeun) ត្រង់ ERN 00991626។ **D11/384/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី អ៊ូច សាខុន (Ouch Sakon) ត្រង់ ERN 00991950។ **D54/22** របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ត្រង់ ERN 00947617-19។ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A26-A29។

[103] **D5/1049/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី (Sam Vuthy) ត្រង់ ERN 00991851។ **D54/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ត្រង់ A4។

[104] **D54/18** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ត្រង់ A15, A18។

[105] **D59/1/1.11a** សម្ភាសន៍ជាមួយ ហ៊ាង រ៉េត (Hieng Ret) ត្រង់លេខ ERN 00974121 ។ **D54/43** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី លុន សេង (Lon Seng) ត្រង់លេខ A17-A19។

[106] **D54/43** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី លុន សេង (Lon Seng) ត្រង់លេខ A17-A19។

[107] **D54/17** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី សាយ ប៊ន (Say Born) ត្រង់លេខ A14-A15។

[108] **D54/20** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី សំ សោម (Sam Saom) ត្រង់លេខA14 ។ **D59/1/1.1/11a** សម្ភាសន៍ជាមួយ ហ៊ាង រ៉េត (Hieng Ret) ត្រង់លេខ ERN 00974121។

[109] **D54/17** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី សាយ ប៊ន (Say Born) ត្រង់លេខ A15 ។ ឯកសារលេខ **D54/35** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា (Brak Sokha) ត្រង់លេខ A17 ។ ឯកសារលេខ **D54/43** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី លុន សេង (Lon Seng) ត្រង់លេខ A17-A19 ។

[110] **D59/1/1.14** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ហ៊ីង អ៊ុច (Hing Uch) ត្រង់លេខ ERN 01001391។

[111] **D2-16** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ទូច ស៊ឺលី (Touch Soeuli) ត្រង់លេខ A17-A21។

[112] **D54/17** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី សាយ ប៊ន (Say Born) ត្រង់លេខ A15 ។ **D59/1/1.14** សម្ភាសន៍ជាមួយ ហ៊ីង អ៊ុច (Hing Uch) ត្រង់លេខ ERN 01001391។ **D59/1/1.1/11a** សម្ភាសន៍ជាមួយ ហ៊ាង រ៉េត (Hieng Ret) ត្រង់លេខ ERN 00974121។

[113] **D54/43** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី លុន សេង (Lon Seng) ត្រង់លេខ A17-A19 ។

[114] **D59/1/1.1/11a** សម្ភាសន៍ជាមួយ ហ៊ាង រ៉េត (Hieng Ret) ត្រង់លេខ ERN 00974121។

នានានៅក្នុងភូមិពុទ្ធទេ[115] គឺជាមូលដ្ឋាននៃអង្គភាពផលិតដ៏ធំមួយដែល ពួកអតីតទាហ៊ាននៃសាធារណរដ្ឋខ្មែរ និងកងកម្លាំងនៃកងពលធំលេខ១៦៤ ត្រូវបានគេបញ្ជូនទៅកាន់ទីនោះ[116]។ ភស្តុតាងបានចង្អុលបង្ហាញថា នៅឯការដ្ឋានសម្រាប់ធ្វើពលកម្ម កង កេង ពួកពលករត្រូវបានគេបង្ខំឲ្យផលិតឥដ្ឋ[117] កសាងទំនប់ទឹក[118] និងធ្វើស្រែ[119] ហើយដែលត្រូវគេដាក់ឲ្យស្ថិតនៅក្នុងស្ថានភាពដ៏អមនុស្សធម៌[120] ដែលរួមមានការផ្តល់អាហារហូបចុកមិនគ្រប់គ្រាន់[121] និងត្រូវឲ្យធ្វើការងារច្រើនម៉ោង[122]។

គ. មានទីតាំងសម្រាប់ធ្វើពលកម្មដោយបង្ខំជាច្រើន ស្ថិតនៅក្នុងតំបន់រាម។ ក្នុងឆ្នាំ១៩៧៥ មានប្រជាជនយ៉ាងច្រើនត្រូវបានគេផ្ទេរបញ្ជូនដោយប្រើកម្លាំង ឲ្យមកនៅតាមភូមិនានាក្នុងឃុំរាមនេះ[123] ដែលប្រជាជនរាប់ពាន់នាក់ ក្នុងនោះមានស្ត្រី កុមារ មនុស្សវ័យចាស់ និងជនពិការ ត្រូវបានគេឲ្យធ្វើពលកម្មដោយបង្ខំ ដោយមិនគិតពីស្ថានភាពរបស់ពួកគេឡើយ។ ប្រភេទនៃពលកម្មដោយបង្ខំនៅតាមបណ្តាការដ្ឋានទាំងនេះរួមមាន ការដាំស្រូវនៅតាមវាលស្រែ ដាំបន្លែ ជញ្ជូនកំទេចដី និងកសាងទំនប់ទឹក ជីកអុស និង កាប់ដើមដូងសំអាតយកដី[124]។ ពលករទាំងឡាយត្រូវបានគេផ្តល់ឲ្យនូវរបបអាហារដែលមានកម្រិត ហើយឲ្យ

---

[115] **D54/43** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី លុន សេង (Lon Seng) ត្រង់លេខ A17-A19 ។

[116] **D54/43** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី លុន សេង (Lon Seng) ត្រង់លេខ A19។ **D2-6** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ញូង ច្រុង (Nhoung Chrong) ត្រង់លេខ A28 ។

[117] **D54/17** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី សាយ ប៊ន (Say Born) ត្រង់លេខ A14។

[118] **D2-6** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ញូង ច្រុង (Nhoung Chrong) ត្រង់លេខ A27 ។

[119] **D54/20** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី សំ សោម (Sam Saom) ត្រង់លេខA14 ។ **D54/35** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា (Brak Sokha) ត្រង់លេខ A17 ។

[120] **D54/36** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា (Brak Sokha) ត្រង់លេខ A26-A28 ។ **D2-6** កំណត់ហេតុស្តីពីការស្តាប់ចម្លើយ សាក្សី ញូង ច្រុង (Nhoung Chrong) ត្រង់លេខA28 ។

[121] **D54/20** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី សំ សោម (Sam Saom) ត្រង់លេខA14 ។ **D2-6** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ញូង ច្រុង (Nhoung Chrong) ត្រង់លេខA28 ។

[122] **D54/20** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី សំ សោម (Sam Saom) ត្រង់លេខA14 ។

[123] **D11/373/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ អ៊ុង ចាន់ធា (Ung Chan Thea) ត្រង់លេខ ERN 00991658។ **D11/387/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ សំ វុទ្ធី (Sam Vuthy) ត្រង់លេខ ERN 00991850។ **D11/385/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ព្រំ សាម៉ុន (Prum Samon) ត្រង់លេខ ERN 00991815។

[124] **D54/84** កំណត់ហេតុស្តីពីការបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៤ មករា ២០១៤ ត្រង់លេខ ERN 009985281។ **D11/373/1** របាយការណ៍ របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ អ៊ុង ចាន់ធា (Ung Chan Thea) ត្រង់លេខ ERN 00991658។ **D11/385/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ព្រំ សាម៉ុន (Prum Samon) ត្រង់លេខ ERN 00991815។ **D11/387/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យ

ធ្វើការងារក្នុងរយៈពេលយ៉ាងយូរ[125]។ មានពលករជាច្រើនត្រូវគេសម្លាប់[126] ដែលរាប់បញ្ចូលទាំងនៅឯចំការធូរេនផង ដែលបានលើកយកមកពិភាក្សាដូចមានខាងក្រោម។ សហករណ៍មូលដ្ឋាននានានៅរាម រាយការណ៍ជូនកងពលធំលេខ១៦៤ ហើយត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់កងពលនេះ[127]។ រាម ក៏ត្រូវបានកងពលធំលេខ១៦៤ ប្រើប្រាស់ធ្វើជាកំពង់ផែសម្រាប់កងនាវាទ័ពជើងទឹកផងដែរ ហើយកងវរៈសេនាធំលេខ១៤០ មួយផ្នែកបានបោះទីតាំងនៅកពង់ផែនេះ[128]។

២៤. ភស្តុតាងបានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា កងកម្លាំងនៃកងពលធំលេខ១៦៤ និងពួកកម្មាភិបាលមូលដ្ឋានបានអនុវត្តការសម្លាប់មនុស្សនៅទីតាំងពីរកន្លែងដែលស្ថិតនៅក្នុងរង្វង់នៃតំបន់ រាម នេះ។ ទីតាំងមួយនៃទីតាំងទាំងពីរនេះ ត្រូវបានគេពិពណ៌នាថា ជាចំការធូរេនមួយ[129] ដែលមានទីតាំងស្ថិត

---

សុំតាំងខ្លួនជាភាគីដើមបណ្តឹង រដ្ឋប្បវេណី របស់ឈ្មោះ សំ វុទ្ធី (Sam Vuthy) ត្រង់លេខ ERN 0091850។ **D1.3.13.8** សម្ភាសន៍ជាមួយ ប៉ែន សារិន (Pen Sarin) ត្រង់លេខ ERN 00217561។ **D2/6** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ញូង ច្រុង (Nhoung Chrong) ត្រង់លេខ A24-A31។ **D54/18** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី នូ សារឿន (Nou Saroeun) ត្រង់លេខ ERN A24-A26, A30។

[125] **D11/387/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ សំ វុទ្ធី (Sam Vuthy) ត្រង់លេខ ERN 00991850។

[126] *សូមអាន ជាឧទាហរណ៍* **D11/378/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ឌិន កន (Din Kan) ត្រង់លេខ ERN 00991593។ **D11/367/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ សាន សារ៉េត(San Saret) ត្រង់លេខ ERN 00991577, និង **D11/373/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ អ៊ុង ចាន់ ធា (Ung Chan Thea) ត្រង់លេខ ERN 00991658-9។

[127] **D1.3.13.11** សម្ភាសន៍ជាមួយ សៀង (Sieng) ត្រង់លេខ ERN 00217565។

[128] **D54/8** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ដុល សុង (Dol Song) ត្រង់លេខ A23។ **D54/17** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី សាយ ប៊ន (Say Born) ត្រង់លេខ ERN 00977271-2។

[129] **D54/18** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី នូ សារឿន (Nou Saroeun) ត្រង់លេខ A33-A34, A41, និងលេខ A43។ **D2/17** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី អ៊ិន សារឿន (In Saroeun) ត្រង់លេខ A7, លេខ A10-A14។ **D11/375/**1 របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ដុំ គាន (Dom Khean) ត្រង់លេខ ERN 00991692។ **D11/390/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ផេង គឹមឡា (Pheng Kimla) ត្រង់លេខ ERN 00991375-6។ **D11/373/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ អ៊ុង ចាន់ធា (Ung Chan Thea) ត្រង់លេខ ERN 00991659 ។ **D11/360/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ កេត ឡុច (Keth Loch) ត្រង់លេខ ERN។ **D11/376/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ អ៊ឹង អូន (Oeng Aun) ត្រង់លេខ ERN 0091709។ **D11/374/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ នាក់ ស៊ីថា (Neak Sitha) ត្រង់លេខ ERN 00991675។ **D11/370/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ផាន់ រិន (Phan Rin) ត្រង់លេខ ERN 00991609-10។ **D11/387/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹង

នៅក្នុងភូមិរាម ឃុំរាម ដែលនៅទីនោះមានរណ្តៅកប់សពរួមយ៉ាងហោចណាស់ក៏ពីរដែរ[130]។ ជនរងគ្រោះនានាដែលត្រូវគេសម្លាប់នៅទីតាំងនេះ រួមមាន ក្នុងចំណោមជនរងគ្រោះដទៃៗទៀតមាន អ្នកនេសាទត្រីជនជាតិថៃ និងវៀតណាម[131] ប្រជាជនអ្នកដែលបានប្រព្រឹត្តខុស ជនទាំងឡាយណាដែលគេកំណត់អត្តសញ្ញាណថា ជាពួកក្បត់ ជនពិការ និងអ្នកដែលបំពេញភារកិច្ចមិនបានល្អ[132] ។ ភស្តុតាងបានបង្ហាញថា កងវរៈសេនាធំលេខ៦២ នៃកងពលធំលេខ១៦៤ បានសម្លាប់មនុស្សនៅក្នុងចំការនេះ[133]។ ទីកន្លែងសម្លាប់មនុស្សទីពីរ ដែលបានស្គាល់អត្តសញ្ញាណមកទល់ត្រឹមនេះគឺ ចំការដូង ដែលស្ថិតនៅក្នុងតំបន់រាម (ដែលមានចម្ងាយមិនឆ្ងាយប៉ុន្មានពីចំការធូរេន) ដែលនៅទីនោះ កងវរៈសេនាធំលេខ៦២ បានប្រើសម្រាប់សម្លាប់អ្នកទោសជនជាតិវៀតណាម[134]។

## IV. ការដាក់ជូនសេចក្តីសន្និដ្ឋានដើម្បីជាការឆ្លើយតបទៅនឹងការជូនដំណឹង

២៥. នៅក្នុងផ្នែកទីIII មានតែការរៀបរាប់ជាទូទៅដោយត្រួសៗអំពីភស្តុតាងដែលប្រមូលបានចាប់តាំងពីសេចក្តីសម្រេចលើយុត្តាធិការតែប៉ុណ្ណោះ ហើយនៅពេលដែល ការស៊ើបសួរកំពុងតែបន្តដំណើរការនោះ សហព្រះរាជអាជ្ញាអន្តរជាតិ សូមជូនជាយោបល់ថា ភស្តុតាងដែលមានស្រាប់ដែលនៅក្នុងសំណុំរឿងរហូតមកទល់ពេលនេះ បានបង្ហាញឲ្យឃើញការពិត ដោយមានភាពប្រាកដប្រជាថា៖

ក. មាស មុត គឺជាសមាជិកមួយរូបនៃគណៈកម្មាធិការមជ្ឈិមបក្ស បកក ជាសមាជិកនៃបញ្ជាការជាន់ខ្ពស់របស់កងទ័ពបដិវត្តកម្ពុជា ជាអ្នកដែលចូលរួមម្នាក់ នៅក្នុងការងារ

---

រដ្ឋប្បវេណីរបស់ឈ្មោះ សំ វុទ្ធី(Sam Vuthy) ត្រង់លេខ ERN 00991850។ **D11/385/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ព្រំ សាម៉ុន (Prum Samon) ត្រង់លេខ ERN 00991816។

[130] **D54/18** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី នូ សារឿន (Nou Saroeun) ត្រង់លេខ A44, និងលេខ A46-A48។ **D10.1.9** របាយការណ៍ស្តីពីអំពើប្រល័យពូជសាសន៍នៅក្រុងព្រះសីហនុ, ចុះថ្ងៃទី ១៥-១៧ ធ្នូ ១៩៩៥, ត្រង់លេខ ERN 00785445។ **D54/22** កំណត់ហេតុស្តីពីការបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី ២៦ កញ្ញា ២០១៣ ត្រង់លេខ ERN 00947618-19។

[131] **D2/17** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី អ៊ិន សារឿន (In Saroeun) ត្រង់ A10-A11, A15-A24, A27-A28 និង A43។ **D54/18** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី នូ សារឿន (Nou Saroeun) ត្រង់ A36-A39 និង A41-A43។ **D54/22** កំណត់ហេតុស្តីពីការបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី ២៦ កញ្ញា ២០១៣ ត្រង់ ERN 00947618-9។ **D2/6** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ញួង ច្រុង (Nhoung Chrong) ត្រង់ A42។ **D54/26** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A12-A13។ **D2/16** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ទូច សូលើលី (Touch Soleuli) ត្រង់ A32។

[132] **D11/373/1** របាយការណ៍របស់អង្គភាព VSS ស្តីពីពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ អ៊ុង ចាន់ធា (Ung ChanThea), ត្រង់ ERN 00991658 ។ **D2/6** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ញួង ច្រុង (Nhoung Chrong) ត្រង់ A40។

[133] **D2/6** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ញួង ច្រុង (Nhoung Chrong) ត្រង់ A43-A44។ **D54/26** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A13។

[134] **D54/26** កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ A11-A13។

របស់អគ្គសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា ជាមេបញ្ជាការនៃកងពលធំលេខ១៦៤/កងនាវាចរណ៍នៃកម្ពុជាប្រជាធិបតេយ្យ និងជាលេខានៃឃោតភូមិភាគកំពង់សោម។ គាត់ធ្លាប់បានកាន់កាប់ភាគច្រើននៃមុខតំណែងទាំងនេះ នៅទូទាំងអម្លុងរបបខ្មែរក្រហមទាំងមូល។ គាត់មានសិទ្ធិអាចចូលជួបដោយផ្ទាល់ និងប្រាស្រ័យទាក់ទងជាប្រក្រតីជាមួយនឹងថ្នាក់ដឹកនាំនានារបស់ បកក ដែលរួមទាំងជាមួយ ប៉ុល ពត នួន ជា និង សុន សេន ផង។ នៅទូទាំងអម្លុងពេលនៃរបបខ្មែរក្រហម គាត់ត្រូវបានផ្តល់ការទុកចិត្តឱ្យទទួលការខុសត្រូវខាងយោធា និងនយោបាយនៅក្នុងកម្រិតមួយដ៏ខ្ពស់ ដែលរួមទាំងក្នុងការបញ្ជាទៅលើពលទាហានរាប់ពាន់នាក់ លើការដឹកនាំកិច្ចប្រតិបត្តិការ និងសន្តិសុខនៅតាមឆ្នេរសមុទ្រកម្ពុជា លើដែនសមុទ្រ កោះនានា និងនៅក្នុងភូមិភាគបូព៌ា ហើយនិងក្នុងការគ្រប់គ្រងរដ្ឋបាលទៅលើតំបន់កំពង់សោមទាំងមូល។ គាត់មាន និងបានអនុវត្តនូវសិទ្ធិអំណាចក្នុងការសម្រេចចអំពីការរស់ និងស្លាប់នៃមនុស្សរាប់ពាន់នាក់។

ខ. មាស មុត គឺជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានា ដែលរួមមាន៖ ១)ការសម្លាប់ប្រជាជនស៊ីវិលរាប់ពាន់នាក់ ក្នុងនោះមាន៖ ការសម្លាប់ប្រជាជនខ្មែរ និងបរទេសនៅតាមកន្លែងសម្លាប់មនុស្សនានា (ដូចជានៅចំការដូង និងចំការធូរេននៅក្នុងតំបន់កំពង់សោម) នៅលើផ្ទៃសមុទ្រ និងនៅតាមបណ្តាកោះនានាដែលកាន់កាប់ត្រួតត្រាដោយកងពលធំលេខ១៦៤ ។ ២) កិច្ចដំណើរការការងារនៃមន្ទីរសន្តិសុខយ៉ាងហោចណាស់ក៏ពីរដែរ (វត្តឥន្ទញ្ញាណ និងទឹកសាប) នៅក្នុងនោះមានជនរងគ្រោះចំនួនរាប់រយនាក់ ហើយប្រហែលជារាប់ពាន់នាក់ផងដែល ត្រូវគេដាក់គុកឱ្យទទួលរងនូវការធ្វើបាបយ៉ាងអមនុស្សធម៌ និងសម្លាប់ចោល។ ៣) ការសម្លាប់ពួកអ្នកទោសណ្តើយសឹក។ ៤) ការដាក់ឱ្យនៅក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងសម្លាប់ នៅមន្ទីរស-២១ នូវពួកបុគ្គលិកយោធាកម្មាភិបាល និងជនស៊ីវិលដែលគាត់ គឺជាអ្នកដែលផ្តល់ការយល់ព្រម ជួយសម្រួល និងឱ្យបញ្ជាក្នុងការផ្ទេរបញ្ជូនទៅ។ ៥) ការធ្វើឱ្យទៅជាទាសករ និងការធ្វើបាបយ៉ាងអមនុស្សធម៌ ចំពោះជនស៊ីវិលរាប់ពាន់នាក់ និងបានធ្វើការបោសសំអាតពួកទាហានដែលនៅក្នុងការដ្ឋានពលកម្មដោយបង្ខំ និងការដ្ឋានអប់រំកែប្រែនានារួមបញ្ចូលទាំងការដ្ឋានពលកម្មដោយបង្ខំ និងការដ្ឋានអប់រំកែប្រែដែលស្ថិតនៅស្ទឹងហាវ នៅឃុំរាម នៅឃុំបិតត្រាង និង កង កេង ។ ហើយនិង ៦) ការស្លាប់នៅតាមការដ្ឋានពលកម្មដោយបង្ខំ និងការដ្ឋានអប់រំកែប្រែទាំងនេះ។

២៦. ក្នុងការពិនិត្យពិចារណាទៅលើអង្គហេតុ និងភស្តុតាងខាងលើនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមលើកជាមតិថា មាស មុត គឺជាមេដឹកនាំជាន់ខ្ពស់ នៃកម្ពុជាប្រជាធិបតេយ្យផង និងជាអ្នកទទួលលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជាចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ផង។

២៧. ភស្តុតាងដូចដែលបានយកមកពិភាក្សាខាងលើនេះ ក៏បង្កើតបានជា "ភស្តុតាងយ៉ាងច្បាស់លាស់ និងដែលអាចឲ្យជឿបាន"[135]ថា មាស មុត គឺ ជាអ្នកទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មនានាដូចដែលបានចោទប្រកាន់នៅក្នុងសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដូចត្រូវបានបញ្ជាក់បំភ្លឺដោយសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ សហព្រះរាជអាជ្ញាអន្តរជាតិជាបន្តបន្ទាប់មកទៀត[136]។ នៅពេលនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមបញ្ជាក់ជូនថា ការចោទប្រកាន់ចំពោះជនសង្ស័យ គឺជាបញ្ហាដែលអាស្រ័យទាំងស្រុងទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាក៏សូមជូនជាមតិដែរថា ច្រកទ្វារចូលទៅកាន់ភស្តុតាងបានឈានទៅដល់ហើយ ដែលនៅពេលនោះ មាស មុត គួរត្រូវបានធ្វើការកោះហៅ និងធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មនានាដូចដែលបានចោទនៅក្នុងករណីរឿងនេះ។

២៨. អាស្រ័យដោយមូលហេតុដូចដែលបានលើកឡើងខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិសូមៈ

ក) គោរពជូនជាយោបល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរប្រកាន់ខ្ជាប់ថា មាស មុត គឺធ្លាប់ជាមេដឹកនាំជាន់ខ្ពស់ផង និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតផង ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

ខ) គោរពជូនជាយោបល់ថា មានភស្តុតាងយ៉ាងច្បាស់ និងយ៉ាងស៊ីសង្វាក់គ្នាថា មាស មុត គឺជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានា ដូចដែលបានចោទប្រកាន់នៅក្នុងសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដូចដែលបានបញ្ជាក់បំភ្លឺនៅក្នុងដីកាសន្និដ្ឋាន ជាបន្តបន្ទាប់មកទៀតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ អាស្រ័យហេតុនេះ មាស មុត គួរត្រូវទទួលបទចោទប្រកាន់នៅក្នុងពេលនេះ ហើយបន្ទាប់មកទៀតនឹងអាចមានសិទ្ធិក្នុងការចូលពិនិត្យនៅក្នុងមើលសំណុំរឿង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៤ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[135] វិធាន៥៥(៤) នៃវិធានផ្ទៃក្នុង។

[136] **D47/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី ២៤ មេសា ២០១២ និង ២១ មិថុនា ២០១២។ **D102/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យស្ដីពីគុកទឹកសាប, ចុះថ្ងៃទី ២០ មិថុនា ២០១៤។ **D105/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ ស្ដីពីមន្ទីរសន្តិសុខ ៨០៨, ៨០៩, និង ៨១០, ចុះថ្ងៃទី ១ កក្កដា ២០១៤។ **D1/2/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺ, ចុះថ្ងៃទី ១៦ កុម្ភៈ ២០១១។